# គោលការណ៍ ស្តីពីការផ្តល់ តម្លៃដល់អតិថិជន ដោយស្មើភាពគ្នា

ស៊ីអាយអិមប៊ី គ្រុប មានគោលបំណងលើកកម្ពស់អតិថិជន និងសង្គម ដោយកិច្ចខិតខំប្រឹងប្រែង ក្នុងការបង្កើតនូវការប្រើប្រាស់សេវាធនាគារ ប្រកបដោយនិរន្តរភាព។ យើងខ្ញុំចាត់ទុកអតិថិជនរបស់ខ្លួនជាបេះដូងនៃអ្វីៗគ្រប់យ៉ាង ដែលយើងខ្ញុំប្រព្រឹត្ត ហើយយើងខ្ញុំប្តេជ្ញាចិត្ត ក្នុងការផ្តល់បទពិសោធន៍បម្រើសេវាកម្មអតិថិជន តាមស្តង់ដារកម្រិតខ្ពស់បំផុត ដោយផ្តល់តម្លៃដល់ពួកគេ ដោយស្មើភាពគ្នា នៅគ្រប់ពេល ដែលពួកគេប្រាស្រ័យទាក់ទងជាមួយយើងខ្ញុំ។

សេចក្តីទុកចិត្ត របស់អតិថិជនមកលើយើងខ្ញុំ ពិតជាសំខាន់ខ្លាំងណាស់ ហើយយើងខ្ញុំសន្យា ចំពោះអតិថិជនថា យើងខ្ញុំនឹង៖

### ផ្តល់តម្លៃដល់ពួកគេ ដោយស្មើភាពគ្នា

យើងខ្ញុំប្តេជ្ញាចិត្ត ដោយធានាថា អតិថិជនរបស់យើងខ្ញុំមានទំនុកចិត្ត នៅពេលពួកគេប្រាស្រ័យទាក់ទង ជាមួយនឹងស្ថាប័នមួយ ដែលការផ្តល់តម្លៃស្មើភាពគ្នា គឺជាចំណុចស្នូលដ៏សំខាន់ នៃវប្បធម៌របស់ស៊ីអាយអិមប៊ី គ្រុប។

### អនុវត្តការលក់ ដែលសក្តិសមតាមតម្រូវការ

យើងខ្ញុំប្តេជ្ញាចិត្ត ដោយធានាថា ផលិតផលសេវាកម្ម និងលក្ខខណ្ឌរបស់យើងខ្ញុំ ត្រូវបានដាក់លក់ និងរចនាឡើង ដើម្បីបំពេញតាមតម្រូវការរបស់អតិថិជន។

### មានតម្លាភាព

យើងប្តេជ្ញាធ្វើឲ្យប្រាកដថាអតិថិជនរបស់យើងនឹងទទួលបានព័ត៌មានច្បាស់លាស់ ពាក់ព័ន្ធ និងទាន់ពេលវេលាដើម្បីងាយដល់ការសម្រេចចិត្តឲ្យបានច្បាស់។

### ផ្តល់ការប្រឹក្សាយោបល់ ដ៏សក្តិសមបំផុត

យើងខ្ញុំប្តេជ្ញាចិត្ត ដោយធានាថា នៅពេលអតិថិជនទទួលបានការប្រឹក្សាយោបល់ លើផលិតផល និងសេវាកម្ម រាល់ការប្រឹក្សាយោបល់ទាំងអស់នោះ៖ គឺពិតជាសក្តិសមបំផុត សម្រាប់ពួកគេ និងឆ្លើយតបនឹងតម្រូវការជាក់ស្តែងរបស់ពួកគេផងដែរ។

### មានភាពបត់បែន

យើងខ្ញុំប្តេជ្ញាចិត្ត ដោយធានាថា អតិថិជនមិនប្រឈមនឹងបញ្ហា ក្រោយទទួលសេវាកម្ម ដែលបង្កឡើងដោយ ស៊ីអាយអិមប៊ី គ្រុបឡើយ ដូចជាចង់ផ្លាស់ប្តូរផលិតផល ប្តូរអ្នកផ្គត់ផ្គង់សេវាកម្ម ទាមទារសំណង ឬដាក់ពាក្យបណ្តឹងជាដើម។

### ផ្តល់ជូនពួកគេ នូវភាពស្រណុកក្នុងចិត្ត

យើងខ្ញុំប្តេជ្ញាចិត្ត ដោយធានាថា រាល់ទិន្នន័យ និងឯកជនភាពរបស់អតិថិជនទាំងអស់ ត្រូវបានការពារយ៉ាងតឹងរឹងបំផុត។

គោលការណ៍ ស្តីពីសេវាកម្មបម្រើអតិថិជន នឹងបង្ហាញកាន់តែច្បាស់ ពីការប្តេជ្ញាចិត្តរបស់យើងខ្ញុំ ចំពោះអតិថិជន។